# Ordo Salutis

“Ordo salutis”គឺជាឃ្លាក្នុងភាសាឡាតាំងមានន័យថា “លំដាប់លំដោយនៃសេចក្ដីសង្គ្រោះ” ដែលសំដៅទៅលើ ជំហានជាបន្តបន្ទាប់នៃគំនិត ដែលទាក់ទងនឹងសេចក្ដីសង្គ្រោះរបស់គ្រីស្ទបរិស័ទ។ លំដាប់លំដោយនេះត្រូវបានរៀបចំឡើងដើម្បីឲ្យមានលក្ខណៈសមហេតុសមផល ជាជាងតាមលំដាប់លេខរៀង។ ជំហានខ្លះកើតឡើងជាបន្តបន្ទាប់ ប៉ុន្តែជំហានខ្លះទៀតកើតឡើងភ្លាមៗ។ អ្វីដែលនៅខាងក្រោមនេះ គឺជាការយល់ដឹងតាមកំណែទម្រង់ជំនឿបែបបុរាណ (Classically Reformed) អំពីរបៀបដែលព្រះជាម្ចាស់សង្គ្រោះប្រជារាស្ត្ររបស់ទ្រង់។

តម្រុយ៖ ចូរចាប់ផ្ដើមអានពីផ្នែកខាងក្រោមមកមុន

## ការបំពាក់នូវសិរីរុងរឿង

ទីបំផុតព្រះជាម្ចាស់នឹងលុបអស់ទាំងស្លាកស្នាមនៃបាបចេញពីគ្រីស្ទបរិស័ទ ហើយប្រទានឲ្យពួកគេនូវការរស់ឡើងវិញខាងរូបកាយ។

## ការតស៊ូទ្រាំទ្រ

ព្រះជាម្ចាស់នឹងរក្សាអស់អ្នកណាដែលបានរាប់ជាសុចរិត ដោយអំណាចព្រះចេស្ដារបស់ទ្រង់ ហើយពួកគេនឹងតស៊ូទ្រាំទ្រក្នុងជីវិតជាគ្រីស្ទបរិស័ទ រហូតដល់ទីបញ្ចប់នៃជីវិតរបស់ពួកគេ។

## ការញែកចេញជាបរិសុទ្ធ

ការញែកចេញជាបរិសុទ្ធ គឺជាកិច្ចការរបស់ព្រះ និងមនុស្ស ដែលការនោះកំពុងតែកើតឡើងជាបន្តបន្ទាប់ និងមានរយៈពេលពេញមួយជីវិត ដែលរំដោះយើងឲ្យមានសេរីភាពពីអំពើបាប ហើយឲ្យយើងមានលក្ខណៈដូចរូបអង្គព្រះគ្រីស្ទកាន់តែខ្លាំងឡើង។

## ការទទួលធ្វើជាកូនចិញ្ចឹម

ព្រះរាជកិច្ចរបស់ព្រះ ក្នុងការដែលទ្រង់ធ្វើឲ្យយើង ក្លាយជាសមាជិកនៃគ្រួសាររបស់ទ្រង់។

## ការរាប់ជាសុចរិត

ព្រះរាជកិច្ចស្របច្បាប់របស់ព្រះដែលកើតឡើង មួយរំពេចនោះ ក្នុងការដែលទ្រង់ប្រកាសថា ទ្រង់បានអត់ទោសបាបឲ្យយើងហើយ ហើយប្រទានឲ្យយើងនូវសេចក្ដីសុចរិតរបស់ព្រះគ្រីស្ទ ។

## ការប្រែចិត្តជឿ

យើងឆ្លើយតបដោយស្ម័គ្រចិត្តចំពោះការត្រាស់ ហៅរបស់ដំណឹងល្អ ប្រែចិត្តចេញពីបាប ហើយ ដាក់ជំនឿរបស់យើងលើព្រះគ្រីស្ទ ដើម្បីឲ្យបានសេចក្ដីសង្គ្រោះ។

## ការកើតជាថ្មី

ព្រះជាម្ចាស់ប្រទាននូវជីវិតខាងព្រលឹងវិញ្ញាណ ដល់អស់អ្នកណាដែលទ្រង់បានត្រាស់ហៅ ដោយអាថ៌កំបាំង និងប្រកបដោយអធិបតេយ្យ។

## ការត្រាស់ហៅ

ព្រះជាម្ចាស់កោះហៅបណ្ដាជនឲ្យចូលមកឯទ្រង់ តាមរយៈការដែលរាស្ត្រទ្រង់ប្រកាសនូវដំណឹងល្អ ដើម្បីឲ្យពួកគេឆ្លើយតបដោយជំនឿដែលនាំមកនូវសេចក្ដីសង្គ្រោះ។

## ការជ្រើសតាំង

មុនកំណកំណើតផែនដី ព្រះជាម្ចាស់បានជ្រើសរើសមនុស្សមួយចំនួនឲ្យទទួលនូវសេចក្ដីសង្គ្រោះ ដោយសារព្រះទ័យដ៏ល្អ និងប្រកបដោយអធិបតេយ្យរបស់ទ្រង់។

រចនារូបភាពភាសាអង់គ្លេសដោយ៖ www.soapboxstudios.ca
រចនារូបភាពភាសាខ្មែរដោយ៖ plovpit.com
បកប្រែដោយមានការអនុញ្ញាតពីគេហទំព័រ៖ http://www.challies.com
លោកអ្នកមានសេរីភាពក្នុងការថតចំលង បោះពុម្ព ដាក់លើគេហទំព័រ ឬក៏ចែកចាយនូវផ្ទាំងក្រាហ្វិកនេះ តាមបំណងប្រាថ្នារបស់លោកអ្នក។